រាជបណ្ឌិត្យសភាកម្ពុជា

# «ទមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## ភាគបញ្ចប់

អត្ថបទចងក្រងដោយៈ លោកស្រី **ស៊ិន ច័ន្ទអមរា**
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



រូបថត : លោកស្រី ស៊ិន ច័ន្ទអមរា

( នៅសារមន្ទីរជាតិភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ )

## ៩-សេចក្តីសន្និដ្ឋាន

ពិធីសម្ពោធ«វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១» ត្រូវបានប្រារព្ធឡើងពីថ្ងៃទី២៨-២៩ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ១៩២៥ ដើម្បីរំឭកដល់ទាហានបារាំងនិងខ្មែរដែលបានពលីជីវិតនៅក្នុងសង្គ្រាមលោកលើកទី១(១៩១៤-១៩១៨) និងអនុស្សាវរីយ៍នៃការតស៊ូរួមគ្នារវាងទាហានបារាំងនិងខ្មែរ ក្នុងការដណ្តើមយកជោគជ័យលើប្រទេសអាល្លឺម៉ង់។ ចំណុចសំខាន់ពីរដែលគប្បីយកចិត្តទុកដាក់នោះគឺ៖ ការផ្តល់ប្រាក់ចូលនិវត្តន៍សម្រាប់ទាហានទៅច្បាំងនៅប្រទេសបារាំង និងការសម្លាប់បាដេសនៅឃុំក្រាំងលាវ ខេត្តកំពង់ឆ្នាំងនៅខែមេសា ឆ្នាំ១៩២៥។

### ៩.១-ការផ្តល់ប្រាក់ចូលនិវត្តន៍សម្រាប់ទាហានទៅច្បាំងនៅប្រទេសបារាំង

ពួកទាហានខ្មែរដែលនៅរស់ពីការទៅច្បាំងនៅប្រទេសបារាំងនោះ ត្រូវបានទទួលការយកចិត្តទុកដាក់ពីរដ្ឋាភិបាលកម្ពុជា។ ច្បាប់រើត្រែត[1] ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩១៩ នោះបានអនុញ្ញតឱ្យទាហានចេញពីអង្គភាពកងទ័ពក្នុងករណីមានរបួសឬមានជំងឺក្នុងពេលដែលធ្វើសឹកសង្គ្រាមនោះ ដោយត្រូវប្តឹងសុំប្រាក់រើត្រែតមុនផុតកំណត់៥ឆ្នាំគិតតាំងពីវេលាដែលរាជការអនុញ្ញាតឱ្យចេញ។ បន្ទាប់មកក្រឹត្យ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩១៩ បានរំឭកឱ្យប្តឹងសុំប្រាក់រើត្រែតនេះកុំឱ្យហួសពេលកំណត់។

នៅប្រទេសបារាំងអសយដ្ឋានសម្រាប់ទាក់ទងនឹងបញ្ហានេះគឺ ផ្លូវឡងត្រី ផ្ទះលេខ១៧ ក្នុងក្រុងប៉ារីស។ លក្ខខណ្ឌសម្រាប់សុំប្រាក់រើត្រែតដែលច្បាប់បើកឱ្យនោះគឺ ការតម្រូវឱ្យចាងហ្វាងរាជការពេទ្យនៅតំបន់ដែលខ្លួនរស់នៅនោះធ្វើលិខិតបញ្ជាក់អំពីស្ថានភាពសុខភាពនៃទាហានទាំងនោះ(មានរបួសឬមានជំងឺ)[2]។

### ៩.២-ការសម្លាប់បាដេសនៅភូមិក្រាំងលាវ ខេត្តកំពង់ឆ្នាំង នៅខែមេសា ឆ្នាំ១៩២៥

ក្រោយពីពិធីសម្ពោធ«វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១» ត្រូវបានបញ្ចប់នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩២៥ តែជាង១ខែកន្លះក្រោយមក ស្រាប់តែនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩២៥ មានផ្ទុះនូវឧប្បត្តិសម្លាប់លោកបាដេស(Bardez) ចៅហ្វាយខេត្តបារាំង (នៅខេត្តកំពង់ឆ្នាំង) នៅភូមិក្រាំងលាវក្នុងឱកាសដែលលោកចុះទៅទារពន្ធផ្ទាល់ដល់ទីនោះ។ អាជ្ញាធរបានតបតវិញដោយដាក់ឈ្មោះភូមិក្រាំងលាវថាជា«ភូមិតិរច្ឆាន»។ លើសពីនេះ អ្នកភូមិក្រាំងលាវចំនួន១៨នាក់ ដែលជាប់សង្ស័យថាបានសម្លាប់លោកបាដេសនោះ ត្រូវគេនាំយកមកកាត់ទោសនៅសាលាឧក្រិដ្ឋ(Cour criminelle)ក្រុងភ្នំពេញពីថ្ងៃទី៥ ដល់ទី២០ ខែធ្នូ ឆ្នាំ១៩២៥។ មនុស្ស១២នាក់បានទទួលទោស៖ ១នាក់(ទោសប្រហារជីវិត) និង១១នាក់ទៀត(ដាក់ពន្ធនាគារពី៥ឆ្នាំដល់មួយជីវិត)។ អ្នកជាប់ពន្ធនាគារត្រូវបញ្ជូនទៅកោះត្រឡាច។ ក្នុងឱកាសនោះ មានមេធាវីបារាំង៣នាក់ឈ្មោះ លោក Gallet, Lortat Jacob និង Dufond ដែលបានធ្វើដំណើរមកពីទីក្រុងព្រៃនគរបានស្នើឱ្យតុលាការលើកលែងទោសឱ្យអ្នកភូមិក្រាំងលាវ ដោយ

---

[1] រើត្រែត(retraite)គឺនិយោជិកដែលដល់កំណត់អាយុឈប់ធ្វើការដោយត្រូវបានសោធនដែលត្រូវបើកក្នុងម្នាក់ៗ។

[2] រាជកិច្ចរាជការ ឆ្នាំ១៩២៣ ទំព័រ១៧៦: សម្រាប់ពួកទាហានចាស់ដែលបានចូលច្បាំង ឱ្យប្រយ័ត្នពីកំណត់ថ្ងៃខែដែលបើកអំណាចឱ្យប្តឹងទារប្រាក់រើត្រែត។

អះអាងថា៖ «បើអ្នកក្រាំងលាវមិនបានបង់ពន្ធជាស្រូវទេ ពួកគេបានបង់ពន្ធជាឈាមរួចទៅហើយ! បើបារាំងចង់បំភ្លេចរឿងនេះ សូមទៅមើលវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»នោះទៅ[3]!

បច្ចុប្បន្នបំណែកដែលនៅសេសសល់នៃ«វិមានរំឭកដល់អ្នកស្លាប់នៅក្នុងសង្គ្រាមលោកលើកទី១»ត្រូវបានយកមករក្សាទុកនៅក្នុងសារមន្ទីរជាតិក្រុងភ្នំពេញ ក្រោយពីត្រូវបានបំផ្លាញចោលក្នុងសម័យប៉ុលពត។ រូបដំរីធំពីរ គឺដាក់តាំងក្នុងសួនច្បារនៅសងខាងនៃច្រកចូលខាងមុខសារមន្ទីរជាតិ ចំណែកតួវិមានគឺដាក់តាំងនៅសួនច្បារផ្នែកខាងជើង(ច្រកផ្ញើម៉ូតូ-ឡាន)។

**ចប់ដោយបរិបូរណ៍**

រូបថត: ដោយ លោកស្រី ស៊ន ច័ន្ទអមរា នៅសារមន្ទីរជាតិភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩





[3] ស៊ន សំណាង, ការវិវត្តនៃសង្គមកម្ពុជានៅចន្លោះសង្គ្រាមលោកទាំង២ (១៩១៩-១៩៣៩), និក្ខេបបទថ្នាក់បណ្ឌិតប្រវត្តិវិទ្យា សាកលវិទ្យាល័យបារីស៧, ឆ្នាំ១៩៩៥, ទំព័រ៣៥២-៣៥៩។




